# បញ្ឈប់

ចែករំលែក បង្រៀន ចុះដល់មូលដ្ឋាន ការពារ

**ជំងឺរលាកស្រោមខួរ (MENINGITIS)**

ជូនចំពោះមាតាបិតា៖

ខ្ញុំសរសេរសំបុត្រនេះដើម្បីអោយលោក-អ្នកបានដឹងអំពីថ្នាំបង្ការដ៏សំខាន់មួយដែលអាចជួយការពារ បុត្រធីតាវ័យជំទង់របស់លោក-អ្នកពីជំងឺរលាកស្រោមខួរ ដែលជាការបង្ករោគដោយបាក់តេរីកើតមានយ៉ាងកំរ ប៉ុន្តែប្រកបដោយគ្រោះថ្នាក់ដែលអាចបង្កអោយមានជំងឺរលាកស្រោមខួរ និងការរាលដាល នៃមេរោគពាសពេញចរន្តឈាម។ គេហៅវាថាថ្នាំបង្ការរលាកស្រោមខួរសមាស ហើយការិយាល័យរបស់យើងខ្ញុំ និងមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (Centers for Disease Control and Prevention, CDC) ណែនាំអោយផ្តល់ថ្នាំបង្ការនេះទៅគ្រប់ក្មេងជំទង់ទាំងអស់ ពីអាយុ11ដល់18ឆ្នាំ ប្រសើរបំផុតនោះគឺនៅពេលពិនិត្យសុខភាពប្រចាំឆ្នាំនៅអាយុ11-12ឆ្នាំរបស់ពួកគេ។

ចំនួនករណីនៃជំងឺរលាកស្រោមខួរប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។ ចាប់តាំងពីឆ្នាំ 1998 រហូតដល់ឆ្នាំ 2007 ពលរដ្ឋអាមេរិកប្រហែល 1500នាក់ កើតជំងឺនេះក្នុងមួយឆ្នាំៗ ហើយប្រហែលម្នាក់ក្នុងចំនោមប្រាំបួននាក់បានស្លាប់។ ក្មេងជំទង់និងមនុស្សធំវ័យក្មេងងាយរងគ្រោះជាពិសេសទៅនឹងការបង្ករោគនេះ។ ជាការពិត ជិត15ភាគរយនៃករណីជំងឺរលាកស្រោមខួរទាំងអស់កើតមានលើក្មេងជំទង់ និងមនុស្សធំវ័យក្មេង ហើយមនុស្សប្រហែលម្នាក់ក្នុងចំនោមប្រាំពីរនាក់បានស្លាប់បាត់បង់ជីវិត។

កត្តាមួយចំនួនទាក់ទងនឹងរបៀបផែនជីវិតរស់នៅបានដាក់មនុស្សវ័យជំទង់និងមនុស្សធំវ័យក្មេងអោយ ប្រឈមនឹងគ្រោះថ្នាក់កើតជំងឺនេះ។ កត្តាទាំងនេះរួមមានការស្ថិតនៅក្នុងស្ថានភាពរស់នៅជាក្រុម (ការបោះជំរុំគេងក្រៅផ្ទះ អន្តេវាសិកដ្ឋាន) លំនាំនៃការទទួលទានដំណេកមិនទៀងទាត់ និងការប៉ះពាល់ជិតស្និទ្ធនឹងអ្នកមានជំងឺ (ដែលអាចនឹងមិនបង្ហាញរោគសញ្ញានៃជំងឺខ្លួនឯង)។

រោគសញ្ញាដើមដំបូងនៃជំងឺអាចត្រូវបានគេធ្វើរោគវិនិច្ឆ័យខុសយ៉ាងងាយថាជាជំងឺដោយសារវីរុស ដូចជាគ្រុនផ្តាសាយជាដើម ប៉ុន្តែនៅពេលវាចាប់ផ្តើមហើយនោះ ជំងឺរលាកស្រោមខួរអាចវិវត្តន៍ទៅមុខយ៉ាងរហ័សហើយ បណ្តាលអោយស្លាប់ក្នុងរយៈពេល48ម៉ោង។ អ្នករស់រានមានជីវិត រួចផុតពីជំងឺនេះរហូតដល់ម្នាក់ក្នុងចំនោមប្រាំនាក់នឹងរងគ្រោះដោយពិការភាពជាអចិន្ត្រៃយ៍ ដូចជាខូចខួរក្បាល ថ្លង់ ប្រកាច់ ឬត្រូវកាត់ដៃឬជើងចោល។

ដោយការរាប់អាន

---

National Foundation for Infectious Diseases®
www.nfid.org

ការផ្តួចផ្តើមអោយមានការអប់រំជាសាធារណៈត្រូវបាននាំមកជូនលោកអ្នកដោយមូលនិធិជាតិសំរាប់រោគឆ្លង (National Foundation for Infectious Diseases) ក្រោមកិច្ចសហការជាមួយអង្គការនានាដែលឈានមុខផ្នែកថៃទាំសុខភាព។ គោលដៅនៃកម្មវិធីនេះត្រូវបានគាំទ្រដោយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (Centers for Disease Control and Prevention)។ សំរាប់ព័ត៌មានបន្ថែម និងបញ្ជីរាយនាមអង្គការដែលគាំទ្រ និងព័ត៌មានជាធនធានបន្ថែមទៀត សូមចូលទៅកាន់គេហទំព័រ http://stopmeningitis.nfidinitiatives.org។

កម្មវិធីនេះអាចដំណើរការទៅបានដោយជំនួយសំរាប់ការអប់រំឥតកំនត់ដែលផ្តល់ជូនមូលនិធិជាតិសំរាប់រោគឆ្លង (National Foundation for Infectious Diseases) ពីក្រុមហ៊ុនsanofi pasteur។
7/2010